# ទីក្រុងឡុងប៊ិច

ក្រសួងនគរបាល

400 WEST BROADWAY • LONG BEACH • CALIFORNIA 90802 • (562) 570-7260 • FAX (562) 570-7114

**Robert G. Luna**

*ស្នងការនគរបាល*

## នីតិវិធីបណ្តឹងរបស់ប្រជាពលរដ្ឋ

## សេចក្តីផ្តើម

ស្នងការនគរបាល មានអណត្តិស្របច្បាប់ ក្នុងការធានាឱ្យមាននីតិវិធីស៊ើបអង្កេត តាមពាក្យបណ្តឹង ដែលបានដាក់ឡើងដោយសាធារណៈជន ប្រឆាំងនឹងមន្ត្រីក្រសួងនគរបាល ។

មន្ត្រីក្រសួងនគរបាល ត្រូវបានជ្រើសរើស ដោយប្រុងប្រយ័ត្នបំផុត មានការបណ្តុះបណ្តាលជំនាញ ក្នុងកម្រិតខ្ពស់ និងបម្រើការងារ ប្រកបដោយមោទកភាពវិជ្ជាជីវៈ ។ ទោះជាយ៉ាងណាក៏ដោយ ដូចគ្នានឹងអង្គភាពធំៗ ផ្សេងទៀតដែរ ការងាកចេញពីការអនុវត្តមុខងារត្រឹមត្រូវ តែងតែកើតមានឡើង ។ ការចោទប្រកាន់ចំពោះការប្រព្រឹត្តខុសក្រមសីលធម៌ ប្រឆាំងនឹងមន្ត្រីក្រសួង ត្រូវបានស៊ើបអង្កេត យ៉ាងហ្មត់ចត់ និងតាមការពិតជាក់ស្តែង ហើយមាន វិធានការសមស្រប ដោយផ្អែកលើគោលដៅនៃការរក្សាសុច្ចរិតភាពរបស់ក្រសួង និងជំនឿទុកចិត្តរបស់សាធារណៈជន ។

ការគ្រប់គ្រងរដ្ឋបាលសមស្រប លើការអនុវត្តច្បាប់ នឹងអាចធានាបាន លុះណាតែមានការរក្សាបាននូវទីភ្នាក់ងារនគរបាល ប្រកបដោយវិជ្ជាជីវៈខ្ពស់តែប៉ុណ្ណោះ ។ មកទល់បច្ចុប្បន្ននេះ ក្រសួងនគរបាល ទីក្រុងឡុងប៊ិច បានខិតខំប្រឹងប្រែង យ៉ាងយកចិត្តទុកដាក់ ដើម្បីសម្រេចឱ្យបាននូវកម្រិតវិជ្ជាជីវៈខ្ពស់នេះ ហើយយើងខ្ញុំមានបំណងប្រាថ្នា ផ្តល់មធ្យោបាយនានា ដើម្បីរក្សាឱ្យមាននិរន្តរភាព ។

## នីតិវិធី

ពលរដ្ឋគ្រប់រូប មានសិទ្ធិដាក់ពាក្យបណ្តឹង ប្រឆាំងនឹងមន្ត្រីណាម្នាក់ របស់ក្រសួងនគរបាលបាន ។ ពាក្យបណ្តឹង អាចនឹងដាក់ជូនទៅអ្នកមើលខុសត្រូវផ្ទាល់ណាម្នាក់ ឬផ្នែកកិច្ចការផ្ទៃក្នុង ។ ពាក្យបណ្តឹង អាចដាក់បាន ដោយផ្ទាល់ខ្លួន តាមរយៈទូរសព្ទ តាមរយៈសំបុត្រ តាមរយៈអ៊ីម៉ែល ឬតាមរយៈបុគ្គលម្នាក់ ដែលមិនពាក់ព័ន្ធដោយផ្ទាល់ នៅក្នុងឧបទ្ទវហេតុនោះ ។ ពាក្យបណ្តឹង ក៏អាចដាក់បាន ក្នុងលក្ខណៈអនាមិកផងដែរ ។ ក្រសួង នឹងផ្តល់ជូន ទៅដើមបណ្តឹង នូវសេចក្តីប្រកាសអះអាងមួយ ដែលមានចុះហត្ថលេខាផ្ទាល់ខ្លួនរបស់គាត់មួយច្បាប់ នៅពេលមានដាក់ពាក្យបណ្តឹងដោយផ្ទាល់ខ្លួន ។ ពាក្យបណ្តឹង ដាក់ក្នុងលក្ខណៈផ្សេងទៀត នឹងត្រូវផ្ញើជូន ជាសំបុត្រ ។

**នៅពេលទទួលបានបណ្តឹងរួច នីតិវិធីខាងក្រោមនេះ នឹងត្រូវអនុវត្ត :**

1. ពាក្យបណ្តឹង ត្រូវបានបញ្ជូនបន្ត ទៅផ្នែកកិច្ចការផ្ទៃក្នុង ដែលនៅទីនោះ ពាក្យបណ្តឹង នឹងមានចុះលេខឯកសារ ហើយចាត់ចែង ដើម្បីធ្វើការស៊ើបអង្កេត ។

2. បុគ្គល ជាដើមបណ្តឹង នឹងទទួលបានបញ្ញើលិខិតបញ្ជាក់ទទួលស្គាល់ថា ក្រសួងបានទទួលពាក្យបណ្តឹងរួច ហើយមានបញ្ជាក់លេខឯកសារជូន ។

3. នៅពេលបញ្ចប់ការស៊ើបអង្កេត ករណីនេះ នឹងត្រូវបានបញ្ជូនចេញ ទៅ ស្នងការរង និង/ឬ ស្នងការនគរបាល ដើម្បីធ្វើការសម្រេចទោស និងចាត់វិធានការ តាមការសមស្រប ។

4. ក្រោយពេលក្រសួងនគរបាល បានបញ្ចប់ការពិនិត្យឡើងវិញរបស់ខ្លួនលើករណីរួច នោះការពិនិត្យឡើងវិញជាឯករាជ្យមួយ នឹងត្រូវធ្វើឡើង ដោយគណកម្មការបណ្តឹងរបស់ពលរដ្ឋប្រឆាំងនគរបាល (CPCC) ។ ដើមបណ្តឹង នឹងទទួលបានលិខិតមួយច្បាប់ ដែលណែនាំប្រាប់ថា ការស៊ើបអង្កេតបានបញ្ចប់ហើយ និងថាការពិនិត្យឡើងវិញ ទាំងពីរ ត្រូវបានអនុវត្តចប់សព្វគ្រប់ ។

កំណត់សម្គាល់ : រយៈពេល ជាមធ្យម ដែលត្រូវប្រើ ដើម្បីដំណើរការ និងធ្វើការស៊ើបអង្កេត លើពាក្យបណ្តឹងមួយ មានចន្លោះ ពី 3 ទៅ 6 ខែ ប៉ុន្តែ ករណីនីមួយៗ មានលក្ខណៈពិសេសខុសៗ គ្នា ។

| ការិយាល័យរដ្ឋបាល | ការិយាល័យស៊ើបអង្កេត | ការិយាល័យល្បាត | ការិយាល័យគាំទ្រ |
|---|---|---|---|
| (562) 570-5830 | (562) 570-7350 | (562) 570-7214 | (562) 570-7342 |
| ទូរសារ (562) 570-5833 | ទូរសារ (562) 570-5837 | ទូរសារ (562) 570-7058 | ទូរសារ (562) 570-6018 |

# របៀបដាក់ពាក្យបណ្ដឹង

**ព័ត៌មានខាងក្រោមនេះ មានសារៈសំខាន់ណាស់ នៅពេលដាក់ពាក្យបណ្ដឹង :**

- ឈ្មោះ និងសេចក្ដីបរិយាយ, ផ្លាកឈ្មោះ, លេខយានយន្តរបស់មន្ត្រីនគរបាល បើទទួលបាន
- ឈ្មោះ, អាសយដ្ឋាន និងលេខទូរសព្ទ របស់សាក្សី
- ភស្តុតាងផ្សេងទៀត ដែលលោកអ្នកគិតថា អាចនឹងមានសារៈសំខាន់ ដូចជា សំណៅផាកពិន័យ (citations), រូបថត ជាដើម ។
- បើលោកអ្នក មានរងរបួសស្នាម ជាការសំខាន់ណាស់ ដែលលោកអ្នក ត្រូវដាក់ពាក្យបណ្ដឹងរបស់លោកអ្នក ឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ដើម្បីធ្វើការថតរូប ហើយធ្វើកំណត់ត្រាផ្នែកវេជ្ជសាស្ត្រ ឱ្យបានរហ័ស ។

ដើម្បីទទួលបានទម្រង់បែបបទនេះ ជាភាសាផ្សេងៗ ទៀត សូមចូលទៅគេហទំព័រ តាមតំណ :

www.longbeach.gov/police/info/complaints/default.asp

***លោកអ្នក ក៏អាចដាក់ពាក្យបណ្ដឹងរបស់លោកអ្នក តាមអ៊ីម៉ែល ដោយផ្ទាល់បានផងដែរ ទៅអាសយដ្ឋាន :***

Internal.Affairs@longbeach.gov

មន្ត្រីស៊ើបអង្កេត របស់ក្រសួង ធ្វើការខិតខំប្រឹងប្រែង ដើម្បីលាតត្រដាងការពិត នៅក្នុងស្ថានភាពនីមួយៗ ។ ក្នុងករណីទាំងឡាយណា ដែលប្រជាពលរដ្ឋម្នាក់គិតឃើញថា ការស៊ើបអង្កេតត្រឹមត្រូវ មិនត្រូវបានអនុវត្ត នោះប្រជាពលរដ្ឋ អាចទាក់ទងទីភ្នាក់ងារណាមួយ ដូចមាន រាយបញ្ជាក់ជូន ខាងក្រោមនេះបាន :

| | |
|---|---|
| ក្រសួងនគរបាល ទីក្រុងឡុងប៊ិច<br>មេបញ្ជាការ តាមវេនល្បាត (24 ម៉ោង)<br>400 West Broadway<br>Long Beach, CA 90802<br>(562) 570-7236 | គណកម្មការបណ្ដឹងរបស់ពលរដ្ឋ ប្រឆាំងនគរបាល<br>Long Beach City Hall 3rd Floor<br>333 West Ocean Boulevard<br>Long Beach, CA 90802<br>(562) 570-6891 |
| ការិយាល័យមេធាវីប្រចាំឌីស្ទ្រីក ខោនធីឡូអែនជីលែស<br>415 West Ocean Boulevard<br>Long Beach, CA 90802<br>(562) 491-6301 | ក្រសួងនគរបាល ទីក្រុងឡុងប៊ិច<br>ផ្នែកកិច្ចការផ្ទៃក្នុង<br>400 West Broadway<br>Long Beach, CA 90802<br>(562) 570-7343 |
| ការិយាល័យអគ្គមេធាវី<br>រដ្ឋកាលីហ្វ័រញ៉ា<br>សូមផ្ញើជូន : Public Inquiry Unit<br>P.O. Box 94425<br>Sacramento, CA 94244 | គណៈវិនិច្ឆ័យបឋម<br>ខោនធីឡូអែនជីលែស<br>B-303 Criminal Courts Building<br>210 West Temple<br>Los Angeles, CA 90012 |
| ការិយាល័យស៊ើបអង្កេតសហព័ន្ធ<br>501 W. Ocean Boulevard<br>Suite #7370<br>Long Beach, CA 90802<br>(562) 432-6951 | |

ព័ត៌មាននេះ អាចរកបានជាទម្រង់ឯកសារផ្សេងទៀត បាន ដោយស្នើសុំទៅ ប្រធានគ្រប់គ្រងបុគ្គលិក គឺ Karen Owens តាមរយៈទូរសព្ទលេខ (562) 570-7120 ។

# ក្រសួងនគរបាល ទីក្រុងឡុងប៊ិច
# កម្រងសំណួរ
# នៃបណ្តឹងរបស់ប្រជាពលរដ្ឋ

| កាលបរិច្ឆេទ : | ម៉ោង : | P.D.1040.006 (07/13) |
|---|---|---|

| ឈ្មោះភាគីរាយការណ៍ (នាមត្រកូល, នាមខ្លួន, ឈ្មោះកណ្តាល) | # ប័ណ្ណបើកបរ |
|---|---|
| | |

| អាសយដ្ឋាន | ទីក្រុង/រដ្ឋ/ស៊ីបកូដ |
|---|---|
| | |

| ទូរសព្ទទំនាក់ទំនង | ទូរសព្ទផ្សេងទៀត | អាសយដ្ឋានអ៊ីម៉ែល |
|---|---|---|
| | | |

| ភេទ | ជាតិសាសន៍ | ថ្ងៃខែឆ្នាំកំណើត | កាលបរិច្ឆេទ & ពេលវេលា នៃឧបទ្ទវហេតុ | ទីកន្លែងកើតមានឧបទ្ទវហេតុ |
|---|---|---|---|---|
| | | | | |

| ឈ្មោះអ្នកមើលខុសត្រូវផ្ទាល់ ដែលបានទាក់ទង (បើមាន) | # របាយការណ៍ឧបទ្ទវហេតុ / # ទូរសព្ទ / # ទីតាំង (បើដឹង) |
|---|---|
| | |

| បើមានរបួសស្នាម - បរិយាយ អំពីរបួសស្នាម |
|---|
| |

| បើមានពិនិត្យមើល ដោយវេជ្ជបណ្ឌិត - ឈ្មោះ & លេខទូរសព្ទ របស់វេជ្ជបណ្ឌិត |
|---|
| |

| ឈ្មោះនិយោជិត (នានា) / ផ្លាកលេខ (នានា) - (បើមាន), ឬបរិយាយ អំពីនិយោជិត (នានា) |
|---|
| |

| បើមានការពន្យា ក្នុងការរាយការណ៍ - ពន្យល់មូលហេតុ |
|---|
| |

| សរសេររាយបញ្ជាក់ភស្តុតាងមួយចំនួន (វីដេអូ - រូបថត ជាដើម) |
|---|
| |

| ឈ្មោះសាក្សី | អាសយដ្ឋាន/ទីក្រុង/ហ្ស៊ីពកូដ | |
|---|---|---|
| លេខទំនាក់ទំនង | ថ្ងៃខែឆ្នាំកំណើត | # ប័ណ្ណបើកបរ |
| ឈ្មោះសាក្សី | អាសយដ្ឋាន/ទីក្រុង/ហ្ស៊ីពកូដ | |
| លេខទំនាក់ទំនង | ថ្ងៃខែឆ្នាំកំណើត | # ប័ណ្ណបើកបរ |
| ឈ្មោះសាក្សី | អាសយដ្ឋាន/ទីក្រុង/ហ្ស៊ីពកូដ | |
| លេខទំនាក់ទំនង | ថ្ងៃខែឆ្នាំកំណើត | # ប័ណ្ណបើកបរ |

| ឈ្មោះ, អាសយដ្ឋាន & លេខទូរសព្ទ របស់មេធាវី (បើមាន) |
|---|
| |

សម្រាប់តែការប្រើនៅការិយាល័យប៉ុណ្ណោះ

Medical Release Form Yes No Date

Photographs Taken Yes No Date DR# ________________ Received by ____________________

# ក្រសួងនគរបាល ទីក្រុងឡុងប៊ិច
# <u>កម្រងសំណួរ</u>
# <u>នៃបណ្តឹងរបស់ប្រជាពលរដ្ឋ</u>

សូមសរសេររាយបញ្ជាក់ពីរាល់ពាក្យបណ្តឹងទាំងអស់ ដែលមានពាក់ព័ន្ធនឹងឧបទ្ទវហេតុនេះ :

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________ ______________________________

ហត្ថលេខា កាលបរិច្ឆេទ

**លោកអ្នកអាចបំពេញកម្រងសំណួរនេះ ហើយផ្ញើ ជាសំបុត្រ ទៅ : LONG BEACH POLICE DEPARTMENT, ATTENTION INTERNALAFFAIRS DIVISION, 400WEST BROADWAY, LONG BEACH, CA. 90802 ឬផ្ញើតាមទូរសារទៅ : (562) 570-8730**

**ព័ត៌មាននេះ អាចរកបាន ជាទម្រង់ឯកសារផ្សេងទៀតបាន ដោយស្នើសុំទៅប្រធានគ្រប់គ្រងបុគ្គលិក គឺ Karen Owens តាមរយៈទូរសព្ទលេខ (562) 570-7120**